# ដំណឹងជ្រើសរើសបុគ្គលិក

មណ្ឌលព័ត៌មានស្ត្រីកម្ពុជាជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ មិនរកប្រាក់ចំណេញ ដែលប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយប្រពៃណី និង ទំនើប រួមទាំងកម្មវិធីអប់រំតាមសហគមន៍ ដើម្បីរួមចំណែកលើកស្ទួយសមភាពយេនឌ័រ តួនាទី និង តម្លៃស្ត្រីនៅក្នុងគ្រួសារ សហគមន៍ និង សង្គមជាតិ ។ មណ្ឌលព័ត៌មានស្ត្រីកម្ពុជាត្រូវការជ្រើសរើសបុគ្គលិកចំនួន ១ រូប សម្រាប់មុខដំណែង **ការីបញ្ជាម៉ាស៊ីនផ្សាយវិទ្យុស្ត្រី** ។

## ភាពពូកិច្ច

ទទួលបន្ទុកចាក់ផ្សាយកម្មវិធីវិទ្យុ និង ផ្សាយតាមហ្វេសប៊ុក បិទបើកម៉ាស៊ីនផ្សាយប្រចាំថ្ងៃ អធិប្បាយកម្មវិធីកំសាន្ត កម្មវិធីអប់រំនានា ឱ្យមានភាពរលូនសមស្របតាមទស្សនវិស័យ បេសកកម្ម និង គុណតម្លៃ នៃ អង្គការមណ្ឌលព័ត៌មានស្ត្រីកម្ពុជា ។ ផ្តល់យោបល់ ឬ រាយការណ៍អំពីគុណភាព និង កម្លាំងផ្សាយរបស់វិទ្យុជូនអ្នកគ្រប់គ្រងវិទ្យុ ដើម្បីធានាការផ្សាយរបស់វិទ្យុស្ត្រី ប្រកបដោយគុណភាព និង វិជ្ជាជីវៈ ។

## ភារកិច្ច និង ការទទួលខុសត្រូវ

- ប្រចាំការ និងចាក់ផ្សាយកម្មវិធីវិទ្យុ
- បញ្ជាម៉ាស៊ីនផ្សាយ ទាំងការផ្សាយផ្ទាល់តាមវិទ្យុ និង តាមហ្វេសប៊ុកវិទ្យុស្ត្រី
- អធិប្បាយកម្មវិធីកំសាន្ត និង កម្មវិធីផ្សេងៗ
- ចូលរួមជ្រើសរើសបទចម្រៀង បទភ្លេង រូបភាព សម្រាប់ចាក់ផ្សាយ
- ធ្វើកិច្ចការផ្សេងៗ ដូចជា តម្លើងកម្មវិធីវិទ្យុ ថតស្ពត ឌីហ្សាញ កាត់តវីដេអូ
- កត់ត្រាលើតារាងចាក់ផ្សាយប្រចាំថ្ងៃ
- តាមដានការផ្សាយនៅភ្នំពេញ តាមខេត្ត និង រាយការណ៍ជូនអ្នកគ្រប់គ្រង
- គ្រប់គ្រង និង រក្សាទុកឯកសារជាសំឡេងដែលបានផ្សាយរួចហើយ ឲ្យបានត្រឹមត្រូវ
- ទាក់ទងជាមួយវិទ្យុជាដៃគូដែលបានផ្សាយនៅវិទ្យុស្ត្រីអេហ្វអឹម ១០៣.៥

- ត្រៀមសម្ភារៈផ្សេងៗ មុននឹងដំណើរការផ្សាយផ្ទាល់
- គ្រប់គ្រង ថែទាំ សំអាត ឧបករណ៍ សំភារផ្សេងៗ ក្នុងបន្ទប់ផ្សាយផ្ទាល់ និង បន្ទប់ថតសំឡេង ។

**លក្ខណៈសម្បត្តិ**

- មានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិឡើងទៅ ។
- មានបទពិសោធន៍ជាការីបញ្ជាម៉ាស៊ីនផ្សាយយ៉ាងតិច ១ ឆ្នាំ និង ចេះប្រើប្រាស់បណ្តាញសង្គម ។
- មានសម្លេងល្អ ច្បាស់ រួសរាយរាក់ទាក់ ។
- ចូលចិត្តធ្វើការងារប្រព័ន្ធផ្សព្វផ្សាយ ។
- មានអត្តចរិកល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម ចេះធ្វើការងារជាក្រុម ។
- ចេះភាសាខ្មែរ និង អាចប្រើប្រាស់ភាសាខ្មែរច្បាស់លាស់ និយាយ សរសេរ និង អាន ។
- អាចអានភាសាអង់គ្លេសបានខ្លះៗ ។
- មានចំណេះដឹងទូលំទូលាយ អំពីបញ្ហាសង្គម ។
- មានទឹកចិត្តលើកស្ទួយសមភាពយេនឌ័រ លើកកម្ពស់តួនាទីស្ត្រីក្នុងសង្គម និង យល់ដឹងអំពីបញ្ហាទាក់ទងនឹងស្ត្រី ។

បេក្ខជន បេក្ខនារី ដែលមានចំណាប់អារម្មណ៍ សូមផ្ញើលិខិតបញ្ជាក់អំពីចំណាប់អារម្មណ៍ការងារ និង ប្រវត្តិរូបសង្ខេប មកអង្គការមណ្ឌលព័ត៌មានស្ត្រីកម្ពុជា តាមរយៈអ៊ីមែល info@wmc.org.kh ។ ព័ត៌មានលំអិតសូមមើលវេបសាយ https://www.wmc.org.kh ទំព័រហ្វេសប៊ុកវិទ្យុស្ត្រី Women's Radio ។ លេខទូរសព្ទទំនាក់ទំនង ៖ 069 848 013 / 011 780 510

កាលបរិច្ឆេទឈប់ទទួលពាក្យ៖ **ថ្ងៃពុធ ទី ១០ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ៥ ល្ងាច ។**

**សូមអរគុណ**

---